ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

# ដំណឹងជ្រើសរើសគ្រូបង្រៀនទ្រឹស្តី (លើកទី៥)

**យោង៖** ចំណារឯកភាព ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៦ របស់ឯកឧត្តមសាកលវិទ្យាធិការ នៃ ស.វ.ស ផ្សព្វផ្សាយបន្ត។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាសាកលវិទ្យាល័យបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមានវ័យចំណាស់ជាងគេបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ត្រូវការជ្រើសរើស **គ្រូបង្រៀនទ្រឹស្តី ចំនួន ០២រូប ដែលបង្រៀនថ្នាក់ឯកទេស ផ្នែកជំងឺបេះដូង** សម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលត្រូវមានភារកិច្ច និង គុណវុឌ្ឍិ ដូចខាងក្រោម៖

| **ក- ភារកិច្ច៖** | **ខ- គុណវុឌ្ឍិ៖** |
|---|---|
| - ចូលរួមធ្វើបច្ចុប្បន្នភាពមេរៀន<br>- ធ្វើប្លង់មេរៀនតាមការណែនាំ របស់ ស.វ.ស<br>- ស្រាវជ្រាវឯកសារថ្មីៗដែលទាក់ទងនឹងមេរៀន<br>- រៀបចំសំនួរវាយតម្លៃនិស្សិត<br>- រៀបចំប្រគល់សំនួរ និង ចម្លើយគំរូ (បារ៉ែម) មក ម.វ.វ ទៅតាមចំនួន និង កាលបរិច្ឆេទដែលបានកំណត់<br>- ចូលរួមវគ្គបណ្តុះបណ្តាលគរុកោសល្យ របស់ ស.វ.ស<br>- ចូលរួមតាមការចាត់តាំងរបស់ ម.វ.វ និង ស.វ.ស | - មានកម្រិតសញ្ញាបត្រ វេជ្ជបណ្ឌិតឯកទេស ផ្នែកជំងឺបេះដូង ព្រមទាំងមានបទពិសោធន៍ក្នុងវិជ្ជាជីវៈ យ៉ាងតិច ០៣ឆ្នាំ<br>- មាននិក្ខេបបទ<br>- មានបទពិសោធន៍ជាគ្រូណែនាំកម្មសិក្សា នៅតាមមន្ទីរពេទ្យយ៉ាងតិច ០៣ឆ្នាំ<br>- មានចំណេះដឹងភាសាបារាំង ឬ អង់គ្លេស ស្ទាត់ជំនាញ<br>- ចេះប្រើប្រាស់កម្មវិធី Ms. Office<br>- មានសីលធម៌រស់នៅល្អ ថ្លៃថ្នូរ ស្លូតបូត គោរពគ្នាទៅវិញទៅមក និង គោរពវិន័យ ស.វ.ស<br>- មានស្មារតីទទួលខុសត្រូវ និង តម្លាភាពក្នុងការបង្រៀន<br>- មានស្មារតីធ្វើការងារជាក្រុម និងមានភាពអំណត់អត់ធន់ក្នុងការងារ |

**អត្ថប្រយោជន៍ដែលទទួលបាន៖**

- ឱកាសក្នុងការបណ្តុះបណ្តាលជំនាញផ្សេងៗ។

**ព័ត៌មានលម្អិត៖**

- បើបេក្ខជនមានចំណាប់អារម្មណ៍ **សូមទំនាក់ទំនងជាមួយផ្នែកបុគ្គលិក នៃ ស.វ.ស ដើម្បីបំពេញពាក្យសុំបង្រៀន ឬ អាចទាញយកទម្រង់ពាក្យសុំនេះនៅលើវើបសាយ (www.uhs.edu.kh) រួចផ្ញើមកផ្នែកបុគ្គលិក (បន្ទប់ M109) ឲ្យបានមុនថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១៦ វេលាម៉ោង១៦:០០រសៀលជាកំហិត។**
- អាសយដ្ឋានទំនាក់ទំនង៖ ឡូត៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ តាមទូរស័ព្ទលេខ 023 430 559 / 089 383 338 / 077 456 070 / 012 961 529 / 015 575 554 E-Mail: orn_samnang@uhs.edu.kh ។

**បញ្ជាក់៖**

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រក្សាសិទ្ធិក្នុងការធ្វើបញ្ជីឈ្មោះជ្រើសរើសបេក្ខជន (Short List) និង កំណត់ ថ្ងៃខែសម្ភាសន៍ លើកពេលកែប្រែ និង លុបចោលការជ្រើសរើសក្នុងករណីមានភាពមិនប្រក្រតី។
- បេក្ខនារីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែ មីនា ឆ្នាំ២០១៦

**ប្រធានផ្នែកបុគ្គលិក**

ប៊ុន ធីរ៉ាត់